ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខ ៖ ៩៤០/២៤ ក.ប/ខ.ល

## សារលិខិតអបអរសាទរ

**សូមគោរពជូន**

**ឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា អនុប្រធានទី២ ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា**

***ជាទីគោរពដ៏ខ្ពង់ខ្ពស់!***

នាឱកាសដ៏សោមនស្សរីករាយនេះ តាងនាមថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្នុងនាមខ្ញុំបាទ និងភរិយា សូមសម្តែងនូវមនោសញ្ចេតនាយ៉ាងជ្រាលជ្រៅចូលរួមអបអរសាទរជូនចំពោះ **ឯកឧត្តមបណ្ឌិត** ដែលត្រូវបានបោះឆ្នោតជ្រើសរើសជាប់ជា **អនុប្រធានទី២ ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា** ក្នុងសម័យប្រជុំលើកទី២ ព្រឹទ្ធសភានីតិកាលទី៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា និងជាប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** នាថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២៤។

ការទទួលបាននូវការជ្រើសតាំងនេះ គឺជាកិត្តិយសដ៏ធំធេង និងស័ក្តិសមបំផុតសម្រាប់ **ឯកឧត្តមបណ្ឌិត** ដែលបានបូជានូវកម្លាំងកាយ ប្រាជ្ញាស្មារតី និងការធ្វើពលិកម្មសព្វបែបយ៉ាងដើម្បីបុព្វហេតុជាតិ មាតុភូមិ និងបន្តរួមចំណែកក្នុងការដឹកនាំ ការពារបូរណភាពទឹកដី អធិបតេយ្យភាព សុខសន្តិភាព សាមគ្គីភាព ស្ថិរភាពសង្គម និងជំរុញការអភិវឌ្ឍជាតិឱ្យមានការរីកចម្រើនលើគ្រប់វិស័យបន្ថែមទៀត។ យើងខ្ញុំមានជំនឿជឿជាក់ថា ជាមួយនឹងសមត្ថភាព និងបទពិសោធន៍ការងាររបស់ **ឯកឧត្តមបណ្ឌិត** នឹងរួមចំណែកដឹកនាំព្រឹទ្ធសភាឱ្យទទួលបានជោគជ័យ រីកចម្រើនបន្ថែមទៀតលើការពង្រឹងស្ថាប័ននីតិប្បញ្ញត្តិ លទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋនៅកម្ពុជា ឱ្យបោះជំហានទៅមុខកាន់តែរឹងមាំ ក្រោមម្លប់ព្រះបារមី នៃ**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** ជាព្រះប្រមុខរដ្ឋ។

ឆ្លៀតក្នុងឱកាសដ៏ថ្លៃថ្លានេះ យើងខ្ញុំទាំងអស់គ្នា សូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ កែវទាំងបី វត្ថុស័ក្តិសិទ្ធក្នុងលោក ទេវតាថែរក្សាក្នុងព្រះរាជាណាចក្រកម្ពុជា សូមប្រោះព្រំសព្វសាធុការពរ សិរីសួស្តី ជ័យមង្គល វិបុលសុខ ជូនចំពោះ **ឯកឧត្តមបណ្ឌិត** និង**លោកជំទាវ** ព្រមទាំងបុត្រា បុត្រី ចៅប្រុស ចៅស្រី សូមសមប្រកបដោយព្រះពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **ឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា អនុប្រធានទី២ ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា** ទទួលនូវការគោរពដ៏ស្មោះស្ម័គ្រពីយើងខ្ញុំ។

ថ្ងៃ សុក្រ ១៣រោច ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២៤

**តំណាងថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**រដ្ឋមន្ត្រី**

**ហេង សួរ**

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩